


www.newsmekong.org

# កម្មវិធីអាហារូបករណ៍ផ្នែកប្រព័ន្ធផ្សព្វផ្សាយ (២០០៨-០៩)

**Inter Press Service (IPS) Asia-Pacific** និង **Probe Media Foundation Inc (PMFI)** សូមធ្វើការអញ្ជើញ អ្នកសារព័ត៌មាន អ្នកថតរូប និង អ្នកបំរើការផ្នែកទូរទស្សន៍ ដើម្បីចូលរួមដាក់ពាក្យយកអាហារូបករណ៍ក្នុងកម្មវិធីនិមិត្តរូបនៃដងទន្លេមេគង្គរបស់យើង (Imaging Our Mekong) សំរាប់ជុំទី៧ (២០០៨-២០០៩)។ កម្មវិធីអាហារូបករណ៍ប្រចាំឆ្នាំនេះ គឺផ្តោតទៅលើទស្សនះវិស័យនៃតំបន់ទន្លេមេគង្គក្នុងបរិបទសកលភាវូពាណិជ្ជកម្មដែលផ្តោតសំខាន់ទៅលើបញ្ហាដែលជាលទ្ធផលនៃការអភិវឌ្ឍន៍តំបន់។

កម្មវិធី **Imaging Our Mekong** គឺបើកអោយមានការប្រកួតប្រជែងសំរាប់តែប្រទេស កម្ពុជា ឡាវ ថៃ វៀតណាម និងចិន។ សំរាប់អាហារូបករណ៍ក្នុងជុំ ២០០៨-២០០៩ នេះ មាន ៣២ កន្លែង ដែលរួមមាន ១២កន្លែងសំរាប់អ្នកសរសេរអត្ថបទ ៦កន្លែងសំរាប់អ្នកថតរូប និង ១៤កន្លែងទៀតសំរាប់អ្នកយកព័ត៌មានទូរទស្សន៍ (បេក្ខជនទាំងពីរភេទដែលមានបទពិសោធន៍ការងារផ្នែកប្រព័ន្ធផ្សព្វផ្សាយយ៉ាងតិច ៣ ឆ្នាំអាចចូលរួមប្រកួតប្រជែងបាន)។

កម្មវិធី Imaging Our Mekong (www.newsmekong.org) សហការណ៍ដោយ IPS Asia-Pacific and PMFI ដែលត្រូវបានឧបត្ថម្ភដោយអង្គការមូលនិធិ Rockefeller Foundation (South-east Asia) ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ។

កម្មវិធីនេះ ជំរុញអោយមានការវិភាគ បញ្ហាឆ្លងដែនដែលពាក់ព័ន្ធទៅនិងការអភិវឌ្ឍន៍នៃប្រទេស និងសហគមន៍ក្នុងតំបន់ទន្លេមេគង្គ ដោយពិនិត្យមើលអោយគ្រប់ជ្រុងជ្រោយទូទាំងតំបន់នូវព័ត៌មានទាំងឡាយណាជាប់ពាក់ព័ន្ធនិងព័ត៌មានប្រពៃណី ក៏ដូចជានយោបាយ។

គំរោងត្រូវផ្តោតលើការរុករកនូវប្រធានបទឆ្លងដែន (ប្រធានបទដែលផ្សារភ្ជាប់ ឬ ពាក់ព័ន្ធរវាងប្រទេសពីរក្នុងតំបន់) ។ អទិភាពនឹងត្រូវផ្តល់ទៅអោយគំរោងណាដែលមានប្រភព

ផ្សេងៗគ្នាដែលអាចផ្តល់នូវសំលេងតែមួយ និងទិសដៅឆ្ពោះទៅកាន់កត្តាផ្សេងៗ និងមជ្ឈដ្ឋានច្រើនដោយរួមមានក្រុមបន្ទាប់បន្សំ។

បេក្ខជនដែលត្រូវបានជ្រើសរើសត្រូវចេះកែច្នៃប្រធានបទសរសេរ ការថតរូប ក៏ដូចជាភាពយន្តឯកសាររបស់ខ្លួន ដែលប្រធានបទអាចរាប់បញ្ចូលចាប់ពីទំនាក់ទំនងអន្តរជាតិទៅនិងសុខភាពនិងភេទ វប្បធម៌និងជាតិពន្ធ សេដ្ឋកិច្ចនិងបរិស្ថាន និងសមាហរណកម្មសេដ្ឋកិច្ច។

ដំណាក់ការអាហារូបករណ៍រួមមានៈ

ក. ការពិនិត្យ និងការជ្រើសរើសបេក្ខជន (ទំរង់បែបបទនៃពាក្យសុំនិងគំរោងជាភាសាអង់គ្លេស និងភាសានៃប្រទេសតាមដងទន្លេមេគង្គដទៃទៀត អាចរកបាន តាមរយៈការគេហទំព័រ www.newsmekong.org )

ខ. កិច្ចសំភាសន៍នានា ការស្រាវជ្រាវស៊ីជំរៅ ការស៊ើបអង្កេត និងការធ្វើដំណើរទាំងក្នុងនិងក្រៅប្រទេសដោយបេក្ខជនដើម្បីយកព័ត៌មានពាក់ព័ន្ធទៅនឹងប្រធានបទរបស់ខ្លួន។

គ. សរសេរ ឬផលិតនូវការងាររបស់ខ្លួនដែលខ្លួនបានតាមដានរយៈពេល ៥ ខែ ហើយចំពោះអ្នកវិជ្ជាជីវៈខាងទូរទស្សន៍វិញ ត្រូវធ្វើដំណើរទៅប្រទេស ហ្វីលីពីនសំរាប់ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល ៣ សប្តាហ៍ស្តីអំពីភាពយន្តឯកសារ និងផលិតកម្មទូរទស្សន៍។

នៅពេលការចាប់ផ្តើម និងនៅចុងបញ្ចប់នៃជុំអាហារូបករណ៍នីមួយៗ អ្នកដែលជាប់អាហារូបករណ៍ទាំងអស់តម្រូវអោយចូលរួមសិក្ខាសាលាថ្នាក់តំបន់ចំនួនពីរលើកដែលរួមមាន សិក្ខាសាលាបើក (ខែ សីហា ឬ កញ្ញា ២០០៨) និងសិក្ខាសាលាបិទ (ខែ កុម្ភៈ ២០០៩)ដែលពិភាក្សាការងារដែលបានចប់រួចរាល់របស់ខ្លួន។

## លទ្ធផលដែលរំពឹងទុក

ក. <u>អ្នកអាហារូបករណ៍ខាងសារព័ត៌មានៈ</u> អ្នកសរសេរអត្ថបទត្រូវសរសេររឿងអោយបាន ៣០០០ ពាក្យ ហើយចុះផ្សាយនៅក្នុងស្ថាប័នផ្សព្វផ្សាយរបស់ខ្លួន។ ចំពោះអ្នកថតរូបវិញ ត្រូវសរសេរអត្ថបទអោយបាន ៩០០ ពាក្យ ទៅលើរូបថតដែលបានជ្រើសរើសចំនួន ១៥ រូបថត។

ខ. <u>អ្នកអាហារូបករណ៍ខាងទូរទស្សន៍ៈ</u> អ្នកទូរទស្សន៍ត្រូវធ្វើការជាក្រុមដែលមានគ្នាពី ២ ទៅ ៣ នាក់ ដើម្បីផលិតភាពយន្តឯកសាររយៈពេល ១៥-២០ នាទី ហើយបញ្ចាំងតាមរយៈស្ថានីយ៍ទូរទស្សន៍របស់ខ្លួន។ រាល់ឯកសារត្រូវបញ្ជូនជាភាសាអង់គ្លេស។

ពាក្យអាហារូបករណ៍ ក៏ដូចជារឿងដែលត្រូវផលិតក្រោមកម្មវិធី **Imaging Our Mekong** អាចដាក់ជាភាសាក្នុងស្រុកបាន។ ភាសាអង់គ្លេសជាមូលដ្ឋានគ្រឹះដែលតំរូវចាំបាច់អោយអ្នកជាប់អាហារូបករណ៍មាន សំរាប់សិក្ខាសាលាដែលនឹងត្រូវប្រារព្ធនៅពេលចាប់ផ្តើម និងបញ្ចប់នៃកម្មវិធី។

**បេក្ខជនត្រូវបំពេញ ដូចតទៅ:**

- ពាក្យសុំចូលរួមកម្មវិធីអាហារូបករណ៍ Imaging Our Mekong ២០០៨-០៩ ដែលមានសរសេរគំរោងមិនតិចពី ៧០០ ពាក្យ ដោយបង្ហាញពីប្រធានបទឆ្លងដែន និងទិដ្ឋភាពផ្សេងៗគ្នា ប្រធានបទជាទិសដៅដើម្បីសំភាសន៍ ទីតាំងភូមិសាស្ត្រនៃគំរោង និងសេចក្តីពិស្តារដទៃផ្សេងទៀត
- ភ្ជាប់ជាមួយនូវអត្ថបទ ៣ ដែលបានចេញផ្សាយរួចដោយមានដាក់ឈ្មោះរបស់ខ្លួន (សំរាប់អ្នកសារព័ត៌មាន)។ ចំពោះអ្នកថតរូប ត្រូវភ្ជាប់នូវរូបថតចំនួន ៨ ដែលបានចេញផ្សាយរួច។ ចំពោះអ្នកទូរទស្សន៍ ត្រូវភ្ជាប់នូវ VHS, VCD, DVD ឬ Mini DV ដែលថតចំលងអោយបានយ៉ាងហោចណាស់ ២ TV segments ដែលបានបញ្ចាំងក្រោយពីត្រូវបានសរសេរ ដឹកនាំ ឬ កែររួចមក។
- យ៉ាងហោចណាស់អោយមាន ២ references
- លិខិតពីនិពន្ធនាយក ឬ អ្នកគ្រប់គ្រងដែលយល់ព្រមទៅលើពាក្យសុំ និងការធានារហូតដល់ចប់កម្មវិធី Imaging Our Mekong

**ថ្ងៃផុតកំនត់នៃការទទួលពាក្យ គឺ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៨**

សូមផ្ញើរពាក្យទៅតាមអាសយដ្ឋានដូចខាងក្រោម:

The Regional Director
‘Imaging Our Mekong’ c/o IPS Asia-Pacific
Unit 3A, 3rd Flr KSL Tower, 503 Sri Ayutthaya Road,
Phayathai 10400 Bangkok, Thailand
Tel: (66-2) 246 7877/78      Fax: (66-2) 246 7876
Email: imagingourmekong@mac.com or applications@newsmekong.org

*IPS Asia-Pacific (www.ipsnewsasia.net) គឺជាភ្នាក់ងារព័ត៌មានគ្មានគិតពីប្រាក់ចំណេញ ហើយជាមូលនិធិដែលផ្តោតព័ត៌មានទាក់ទងទៅនិង the South ដែលជាផ្នែកបណ្តាញអន្តរជាតិរបស់ IPS និងបង្កើតការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយ។ PMFI (www.probefound.com) គឺជាអង្គការ គ្មានភាគហ៊ុន-គ្មានប្រាក់ចំណេញ ដែលខិតខំប្រឹងប្រែង ដើម្បីការរីកចំរើនគុណភាពនៃប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសទូរទស្សន៍តាមរយៈការបណ្តុះបណ្តាលអ្នកធ្វើការខាងប្រព័ន្ធផ្សព្វផ្សាយដែលមានវិជ្ជាជីវៈនិងអ្នកដែលចង់ចេះ។*

*សូម download ពាក្យសុំ ឬទំរង់បែបបទគំរោងជាភាសាប្រទេសនៅតាមដងទន្លេមេគង្គតាមរយៈគេហទំព័រ www.newsmekong.org*